**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**
**សភាស៊ើបសួរ**
សំណុំរឿងលេខ:៧២
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២
**សាលដីកា**
**លេខ: ៦៩** ស.ស ក្រIV(ព.ជ)
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦/០៧/២០១៤ បានបើកសវនាការជាអសាធារណៈ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹកថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជី

- **ជនត្រូវចោទ:**

១-ឈ្មោះ [redacted] **រ៉ាសន្ថា** ហៅ តក់ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ កើតនិងរស់នៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ស្ថានភាពគ្រួសារ: នៅលីវ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (គេចខ្លួន)

២-ឈ្មោះ [redacted] **ម៉ុនហាំ** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ កើតនិងរស់នៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ស្ថានភាពគ្រួសារ: នៅលីវ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (គេចខ្លួន)

៣-ឈ្មោះ [redacted] **ម៉ុនធឿន** ហៅ យួន ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរកើតនិងរស់នៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ស្ថានភាពគ្រួសារ: នៅលីវ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុណការពីមុន៖ គ្មាន។ (គេចខ្លួន)

៤-ឈ្មោះ [redacted] **សុខា** ហៅ ខា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ កើតនិងរស់នៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ស្ថានភាពគ្រួសារ: នៅលីវ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន ៖ គ្មាន ។ (គេចខ្លួន)

៥-ឈ្មោះ [redacted] **សុខំ** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួននៅភូមិ [redacted]

Scanned with CamScanner

[redacted]ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោស គ្មាន ។ (ម្ចាស់បណ្តឹងឧទ្ធរណ៍)

សព្វថ្ងៃកំពុងឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារ ខេត្តកំពង់ធំ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ ២៧៨ អ.ឃ.ខ/២២ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ។

-មានកញ្ញា [redacted] ចាន់សុផល ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ាំង ។

៦-ឈ្មោះ [redacted] **ឌីម៉ា** ហៅ វ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ កើតនិងរស់នៅភូមិ[redacted]ខេត្តកំពង់ធំ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (រស់)ស្ថានភាពគ្រួសារៈ នៅលីវ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (គេចខ្លួន)

ត្រូវជាក់ស្ដិតក្រោមការពិនិត្យពីបទៈ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន និងបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចជិតស្ពានថ្មដីអាប់ ស្ថិតនៅនៅភូមិសមរម្យ ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ២១ និង ៣០ នាទី បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី៖**

១. ឈ្មោះ [redacted] យុន ភេទស្រី អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (ស្លាប់) ប្តីឈ្មោះ [redacted] មានកូនចំនួន ០៧នាក់ ជានីតិជន ទោសពីមុនគ្មាន ។

២.ឈ្មោះ [redacted] ភឿន ភេទស្រី អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (ស្លាប់) ប្តីឈ្មោះ [redacted] មានកូនចំនួន ០៤នាក់ ជានីតិជន ទោសពីមុនគ្មាន ។

<u>ជនរងគ្រោះ៖</u> ឈ្មោះ [redacted] លីណៃ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកបើករថយន្តឱ្យព្រះសង្ឃវត្តទឹកខ្មៅ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រស់) ម្ដាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

## ១.អំពីរឿងហេតុ

### <u>ក. អំពីអង្គហេតុ</u>

កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ នៅចន្លោះម៉ោង ១៨ ដល់ម៉ោង ២១ និង ០០នាទីយប់ មានក្រុមក្មេងស្ទាវមួយក្រុមមានគ្នាប្រហែល១០នាក់ បានជិះម៉ូតូ ០៧ ទៅ ០៨គ្រឿង ឆាបចុះឆាបឡើងតាមកញ្ចះអង្គុយលេងទាំងសងខាងអូរមាន និង តាមភូមិផងដែរ ដើម្បីរកឈ្មោះ [redacted] ត្រា និង ឈ្មោះ សិទ្ធ តែរកមិនឃើញ ហើយក្នុងចំណោមក្មេងស្ទាវនោះមានម្នាក់ត្រូវបានគេស្គាល់ថាឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិ[redacted]ខេត្តកំពង់ធំ។ ក្រុមនេះបានជិះម៉ូតូចុះឡើងៗរហូតដល់ម៉ោង ២១ជាង ទើបជិះចេញពីតំបន់អូរមានមកឈប់នៅមុំស្ពានដីអាប់ ក្នុងភូមិសមរម្យ ឃុំមានជ័យ ដើម្បីចាំស្ទាក់វាយគូជម្លោះ។ លុះដល់ម៉ោង ២១ និង ៣១នាទី មានម៉ូតូមួយគ្រឿងឌុបគ្នាពីរនាក់ជិះមកតាមក្រោយ ហើយក្រុមនេះបានហៅឲ្យឈប់រួចសួររកឈ្មោះ [redacted] ត្រា និង ឈ្មោះ សិទ្ធ។ ពេលនោះជនរងគ្រោះបានឆ្លើយថា "មិនឃើញនោះទេ ហើយក៏មិនស្គាល់លេខទូរសព្ទគេដែរ" ហើយក្រុមរបស់ឈ្មោះ [redacted] សុខា បាននិយាយថា "ក្រុមវាហើយ វាយវាទៅ"។ ភ្លាមនោះពួកវាក៏ព្រួតគ្នាវាយមកលើជនរងគ្រោះតែម្តង បណ្តាលឲ្យឈ្មោះ វិញ [redacted] ត្រា ហៅម៉េង ភេទប្រុស អាយុ ១៥ឆ្នាំ របួសក្បាលធ្ងន់ធ្ងរ ហើយបានស្លាប់តាមផ្លូវពេលបញ្ជូនមកកាន់មន្ទីរពេទ្យ និងម្នាក់ទៀតឈ្មោះ [redacted] លីណា ភេទប្រុស របួសធ្ងន់ (ត្រូវបុងចិញ្ចើម និង បាក់ដៃឆ្វេង)។

- បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ២៧៨អឃខ/២២ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ធំ។

Scanned with CamScanner

- បានឃើញ ពាក្យសុំធានាឲ្យកូនក្ដីនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ របស់លោក [redacted] សារឿន ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ។

- បានឃើញ ដីកាសម្រេចមិនអនុញ្ញាតដោះលែងឱ្យនៅក្រៅឃុំលេខៈ ៥០៦៧ /២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តកំពង់ធំ ដែលបានសម្រេចៈ

មិនព្រមដោះលែងជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ (ដូចខាងលើ) ដែលត្រូវឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នទេ ។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខៈ១៤៥២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់មេធាវី [redacted] សារឿន ដែលជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ។

- បានឃើញ របាយការណ៍ ចុះថ្ងៃទីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

## ខ. កិច្ចពិភាក្សាដេញដោល

## ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

## ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ជនត្រូវចោទឈ្មោះ [redacted] ស៊ាំង បានឆ្លើយថាៈ មូលហេតុដែលខ្លួនប្ដឹងឧទ្ធរណ៍ ដោយសារតែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយនៅថ្ងៃកើតហេតុនោះ គឺខ្លួនបាននៅផ្ទះជាមួយប្រពន្ធ និងបានហូបចុកជាមួយមិត្តភ័ក្ដ បងប្អូន ព្រមទាំងបានហូបជាមួយអ្នកជិតខាងទៀតផង ។ ប្រសិនបើខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួនប្រាកដជារត់គេចខ្លួនបាត់ទៅហើយ តែនេះដោយសារតែខ្លួនមិនបានប្រព្រឹត្ត ទើបខ្លួនមិនរត់គេចខ្លួនទៅណានោះទេ។ ខ្លួនមានកូនតូចអាយុទើបតែ ១ឆ្នាំ ៨ខែ ដែលត្រូវធ្វើការរកស៊ីចិញ្ចឹមបីបាច់ និងមានប្រពន្ធដែលត្រូវមើលថែ ខ្លួនមានទីលំនៅច្បាស់លាស់ នៅពេលនេះខ្លួនសូមស្នើសុំឲ្យតុលាការដោះលែងខ្លួនឲ្យមានសេរីភាពវិញ ។

- តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ការសួរដេញដោលនៅក្នុងពេលសវនាការ មេធាវីបានប្ដឹងនឹងដីកាសម្រេចមិនអនុញ្ញាតដោះលែងឲ្យនៅក្រៅឃុំលើជនត្រូវចោទ ជនត្រូវចោទជាជនក្រីក្រពុំមានអ្នកជួយរកស៊ីចិញ្ចឹមគ្រួសារ តំណាងមហាអយ្យការមិនមានអ្វីជំទាស់នោះទេទាក់ទងនឹងការស្នើសុំនៅក្រៅឃុំនេះ។

- មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទបានធ្វើសេចក្ដីសន្និដ្ឋានថាៈ មូលហេតុដែលខ្លួនស្នើសុំឲ្យកូនក្ដីនៅក្រៅឃុំ ដោយហេតុថាកូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយសារតែនៅថ្ងៃកើតហេតុនោះគឺកូនក្ដីខ្លួនបាននៅផ្ទះប្រពន្ធរបស់ខ្លួននៅក្នុងភូមិអង្គសែនជ័យ ឃុំក្លែង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដោយមានការជួបជុំផឹកស៊ី ជាមួយបងប្អូន មិត្តភ័ក្ដ ហើយចំពោះការផឹកស៊ីនោះគឺកូនក្ដីខ្លួនបានផឹកស៊ីនៅផ្ទះ ហើយក៏បានបន្តទៅផឹកនៅផ្ទះរបស់ឈ្មោះ [redacted] កាន ដែលមានផ្ទះនៅទល់មុខគ្នា គ្រាន់តែឆ្លងថ្នល់ដល់ ហើយឈ្មោះ [redacted]កាន ជាក្រុមប្រឹក្សាភូមិអង្គសែនជ័យ ក៏បានធ្វើជាសាក្សីហើយបានឆ្លើយបញ្ជាក់ថា កូនក្ដីខ្លួនឈ្មោះ [redacted] ស៊ាំង បានទៅផឹកនៅផ្ទះគាត់រហូតដល់ម៉ោង ២២ ជាងលុះព្រឹកឡើងកូនក្ដីខ្លួនបាននាំកូនទៅមន្ទីរពេទ្យ ឈ្មោះ ភូមិយើង ហើយខាងមន្ទីរពេទ្យក៏បានចេញវិក័យប័ត្រដែលជាលទ្ធផលដែលបានពិនិត្យរួចមកឲ្យហើយដែរ ទាំងនេះជាភស្តុតាងបានបញ្ជាក់ថា កូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ម្យ៉ាងវិញទៀត កូនក្ដីខ្លួនត្រូវជាជនក្រីក្រ ត្រូវធ្វើការរកស៊ី ដើម្បីចិញ្ចឹមប្រពន្ធ និងកូនតូចដែលមានអាយុទើបតែ ១ឆ្នាំ ៨ខែ នៅឯផ្ទះ ដោយគ្មានអ្នកណាជាអ្នកចិញ្ចឹមបីបាច់នោះទេ ។ ហេតុដូចនេះ ខ្លួនសូមស្នើសុំឲ្យក្រុមប្រឹក្សាមេត្តា សម្រេចឲ្យកូនក្ដីខ្លួនបាននៅក្រៅឃុំមានសេរីភាព ឡើងវិញ ។

- សំណូមពរចុងក្រោយរបស់ជនត្រូវចោទៈ ខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះដោះលែងខ្លួនឲ្យបាននៅក្រៅឃុំផង។



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ
-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## ២. សំអាងហេតុ

### សភាស៊ើបសួរ យល់ឃើញថា:

២-១. ពាក្យបណ្តឹងឧទ្ធរណ៍លេខ:១៤៩២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់មេធាវី [redacted] សាឡឿន ដែលជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ដែលបានសុំប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនអនុញ្ញាតដោះលែងឱ្យនៅក្រៅឃុំលេខ:៥០៦៧/២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ធំ ធ្វើឡើងតាមកាលកំណត់ច្បាប់ នៃមាត្រា ២៦៧, ២៧០ និងមាត្រា២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសភាស៊ើបសួរនៃសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-២. នាពេលសវនាការមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ ក៏ដូចជាជនត្រូវចោទបានបញ្ជាក់អំពីមូលហេតុនៃបណ្តឹងឧទ្ធរណ៍ ក៏ដូចជាស្នើសុំឲ្យសភាស៊ើបសួរសម្រេចឲ្យជនត្រូវចោទបាននៅក្រៅឃុំបណ្តោះអាសន្នដោយបានលើកហេតុផលថាមូលហេតុដែលខ្លួនស្នើសុំឲ្យកូនក្តីនៅក្រៅឃុំ ដោយហេតុថាជនត្រូវចោទ មិនបានប្រព្រឹត្តដូចការចោទប្រកាន់ ដោយពុំមានមូលហេតុនៃការឃុំខ្លួនលើជនត្រូវចោទនោះទេ។ ម្យ៉ាងទៀតជនត្រូវចោទមានអាសយដ្ឋានច្បាស់លាស់ ពុំមានផ្ទះនៅទីណាទៀតនោះទេ ហើយជនត្រូវចោទក៏មានមុខរបរពិតប្រាកដដែរ។

២-៣. តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងពេលសវនាការមេធាវីបានប្តឹងនឹងដីកាសម្រេចមិនអនុញ្ញាតដោះលែងឲ្យនៅក្រៅឃុំលើជនត្រូវចោទ ជនត្រូវចោទជាជនក្រីក្រពុំមានអ្នកជួយរកស៊ីចិញ្ចឹមឡើយ តំណាងមហាអយ្យការមិនមានអ្វីជំទាស់នោះទេទាក់ទងនឹងការស្នើសុំនៅក្រៅឃុំនេះ។

២-៤. ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនលើជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ដោយបានលើកសំអាងថា:

- មានការត្រូវរ៉ូវគ្នាជាមួយជនដែលពាក់ព័ន្ធ ឬ ជនដែលមានផលប្រយោជន៍
- ដើម្បីបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- វិធានការស្តីពីការដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគ្មានលក្ខណៈគ្រប់គ្រាន់ និងតឹងរ៉ឹង ។

២-៥. ទាក់ទងនឹងសំអាងហេតុខាងលើ សភាស៊ើបសួរពិចារណាឃើញថា:

- ជនត្រូវចោទមានទីលំនៅច្បាស់លាស់គឺ មានទៅលំនៅបច្ចុប្បន្ននៅភូមិនៅភូមិអង្គរសែនជ័យ ឃុំក្លែង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។
- ជនត្រូវចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង។
- ជនត្រូវចោទជាជនក្រីក្រដែលពុំមានអ្នកជួយរកស៊ីចិញ្ចឹមគ្រួសារ។
- ជនត្រូវចោទមានកូនតូចទើបតែអាយុ១ឆ្នាំ ៨ខែ ដែលត្រូវមើលថែ។
- មេធាវីការពារសិទ្ធិ រួមទាំងជនត្រូវចោទផងដែរក៏បានធានាចំពោះមុខអង្គសវនាការខ្លួននឹងចូលរួមតាមការកោះហៅគ្រប់នីតិវិធីរបស់តុលាការ។

២-៦. ជាគោលការណ៍ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនលើជនត្រូវចោទដោយពិចារណា និងសម្រេច ផ្អែកតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២០៤ និង ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅក្នុងការអនុវត្តបញ្ញត្តិពិសេសនេះ ចៅក្រមស៊ើបសួរមិនត្រូវផ្តោតតែទៅលើ លក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធី

Scanned with CamScanner

ព្រហ្មទណ្ឌប៉ុណ្ណោះទេ គឺត្រូវពិចារណាអំពើល្មើសដែលទទួលរងការចោទប្រកាន់ក៏ត្រូវលើកមកពិចារណាដែរ
ឃើញថានៅក្នុងរឿងនេះ ភាពពាក់ព័ន្ធរបស់ជនត្រូវចោទទៅនឹងការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់គឺ
ពុំមានមូលហេតុចាំបាច់ដែលត្រូវរក្សាទុកជនត្រូវចោទក្នុងឃុំនោះឡើយ។ ក្នុងស្ថានភាពបែបនេះគោលការណ៍
សេរីភាពរបស់ជនត្រូវចោទដោយផ្អែកតាមបញ្ញត្តិមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាគោលការណ៍ចាំបាច់
ដើម្បីធានាដល់សិទ្ធិសេរីភាពបុគ្គល ដែលគប្បីត្រូវតែយកមកអនុវត្តជាបន្ទាន់។

២-៧. ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យឃើញថា មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងអំពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវយកមកអនុវត្តលើពិរុទ្ធជនការមួយចំនួន។

២-៨. សរុបមកឃើញថាដីកាសម្រេចមិនអនុញ្ញាតដោះលែងឱ្យនៅក្រៅឃុំលេខ:៥០៦៧/២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់ សាលាដំបូងខេត្តកំពង់ធំ មិនមានលក្ខណៈត្រឹមត្រូវនោះទេ គប្បីសភាស៊ើបសួរសម្រេចបដិសេធចោល។

## ៣. ផ្នែកសេចក្តីសម្រេច

### ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

៣-១. ទទួលបណ្តឹងឧទ្ធរណ៍លេខ:១៤៩២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់មេធាវី [redacted] សារឿន ដែលជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-២. បដិសេធដីកាសម្រេចមិនអនុញ្ញាតដោះលែងឱ្យនៅក្រៅឃុំលេខ: ៥០៦៧/២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តកំពង់ធំ ចោលជាអសារបង់។

៣-៣. បង្គាប់ឲ្យដោះលែងជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន (ប្រសិនបើជននេះ មិនត្រូវបានឃុំខ្លួនបទល្មើសផ្សេង) ។

៣-៤. ដាក់ជនត្រូវចោទឈ្មោះ [redacted] ស៊ាំង ឲ្យជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវ តុលាការដូចខាងក្រោម៖

-មិនត្រូវផ្លាស់ប្តូរលំនៅឋាន ដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

ក្នុងករណីដែលជនត្រូវចោទគេចវេសដោយចេតនា ពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការខាងលើ ចៅក្រមស៊ើបសួរអាចនឹងចាប់ឃុំខ្លួនជនត្រូវចោទវិញ យោងតាមបញ្ញត្តិមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-៥. សាលដីកានេះប្រកាសជាអសាធារណៈ នៅថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ និងបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ត្បូងឃ្មុំ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner